# មេរោគគ្រុនផ្តាសាយ

## ប្រការសំខាន់ៗស្តីអំពីជម្ងឺ គ្រុនផ្តាសាយ និងថ្នាំបង្ការគ្រុនផ្តាសាយ

## តើជម្ងឺគ្រុនផ្តាសាយជាអ្វី?

គ្រុនផ្តាសាយគឺជាជម្ងឺផ្លូវដង្ហើមដែលឆ្លង បង្កឡើងដោយមេរោគគ្រុនផ្តាសាយ ។ មេរោគនេះអាចបង្កអោយមានជម្ងឺធម្មតា ឬធ្ងន់ធ្ងរបាន ហើយជួនកាលអាចអោយបាត់បង់ជីវិតទៀតផង។ មនុស្សខ្លះដូចជាមនុស្សចាស់ កុមារ និងអ្នកមានស្ថានភាពសុខភាព ជាក់លាក់មួយចំនួនអាចមានហានិភ័យខ្លាំងទៅនឹង ផលវិបាកនៃជម្ងឺគ្រុនផ្តាសាយធ្ងន់ធ្ងរ ។

## រោគសញ្ញានៃជម្ងឺគ្រុនផ្តាសាយ

រោគសញ្ញានៃគ្រុនផ្តាសាយរួមមាន:

- គ្រុនក្តៅ • ឈឺក្បាល • ឈឺសាច់ដុំ • អស់កម្លាំងខ្លាំង • ក្អកស្ងួត • ឈឺក • ហៀរសំបោរ ឬតឹងច្រមុះ
- រោគសញ្ញាឈឺក្រពះ ដូចជា ចង្អោរ ក្អួត និងរាគជាដើម ក៏អាចកើតមានឡើងដែរ ប៉ុន្តែច្រើនកើតមានឡើងចំពោះកុមារ ។

## ផលវិបាកនៃជម្ងឺគ្រុនផ្តាសាយ

ផលវិបាកនៃជម្ងឺគ្រុនផ្តាសាយអាចរួមមានដូចជា រលាកសួតបណ្តាលមកពីបាក់តេរី ខ្សោះជាតិទឹកព្រមទាំង ធ្វើអោយស្ថានភាពជំងឺរ៉ាំរ៉ៃ ធ្ងន់ធ្ងរឡើងដូចជា ជំងឺគាំងបេះដូង ហឺត ឬទឹកនោមផ្អែម។ កុមារអាចមានបញ្ហារលាករន្ធឆ្អឹងច្រមុះ និងការឆ្លងរោគក្នុងត្រចៀក ជាដើម ។

## របៀបឆ្លងនៃជម្ងឺគ្រុនផ្តាសាយ

មេរោគគ្រុនផ្តាសាយឆ្លងដោយសារតំណក់ទឹកតូចៗតាមផ្លូវដង្ហើមបណ្តាលមកពីក្អក និងកណ្តាស់ជាដើម ។ តាមធម្មតា តំណក់ទឹកតូចៗទាំងនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ប៉ុន្តែជួនកាលមនុស្សអាចឆ្លងមេរោគ ដោយការប៉ះពាល់អ្វីមួយដែលមានជាប់មេរោគគ្រុនផ្តាសាយ រួចហើយទៅប៉ះពាល់មាត់ ឬច្រមុះរបស់ខ្លួន ។ មនុស្សពេញវ័យមានសុខភាពល្អ ភាគច្រើន អាចចម្លងទៅអ្នកផ្សេងទៀត តាំងពីថ្ងៃទីមួយ មុនចាប់ផ្តើមឃើញមានរោគសញ្ញា រហូតដល់5ថ្ងៃក្រោយពេលធ្លាក់ខ្លួនឈឺ ។ មានន័យថា យើងអាចចម្លងជម្ងឺគ្រុនផ្តាសាយទៅមនុស្សម្នាក់ទៀតតាំងពីមុនយើងដឹងថា យើងមានជម្ងឺ និងពេលដែលយើងដឹងថា ខ្លួនមានជម្ងឺផងដែរ ។

## ការបង្ការជម្ងឺគ្រុនផ្តាសាយ: ទទួលថ្នាំបង្ការ

មធ្យោបាយដ៏ល្អតែមួយគត់ដើម្បី បង្ការជម្ងឺគ្រុនផ្តាសាយ គឺត្រូវទទួលថ្នាំបង្ការគ្រុនផ្តាសាយរៀងរាល់ឆ្នាំ រវាងខែតុលា និងខែធ្នូ។ ថ្នាំបង្ការមានពីរប្រភេទ:

- "ការចាក់ថ្នាំបង្ការ" - ថ្នាំបង្ការដែលធ្វើអោយអសកម្ម Inactivated Vaccine (មានមេរោគដែលត្រូវបានសំលាប់) ដោយចាក់នឹងម្ជុល។ ការចាក់ថ្នាំបង្ការនេះ ត្រូវបានទទួលការយល់ព្រម អោយប្រើប្រាស់ចំពោះមនុស្សដែលមានអាយុលើសពី 6ខែឡើងទៅ រួមទាំងមនុស្សមានសុខភាពល្អ និងមនុស្សដែលមានស្ថានភាពសុខភាពរ៉ាំរ៉ៃផងដែរ។
- ថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយបាញ់ដាក់ ច្រមុះ ជាថ្នាំបង្ការម៉្យាង ធ្វើពីមេរោគគ្រុនផ្តាសាយដែលនៅរស់តែខ្សោយ ដែលមិនបង្កអោយមានជម្ងឺគ្រុនផ្តាសាយ (ជួនកាលគេហៅថា LAIV ជាពាក្យបំព្រួញថា Live

Attenuated Influenza Vaccine - ថ្នាំបង្ការជម្ងឺគ្រុនផ្តាសាយចុះខ្សោយនៅមានជីវិត) ។ LAIV ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ចំពោះមនុស្សដែលមានសុខភាពល្អ ចាប់ពីអាយុ05ឆ្នាំ ដល់ 49ឆ្នាំ ដែលពុំមានផ្ទៃពោះ។

ប្រហែលពីរសប្តាហ៍ក្រោយពីទទួលថ្នាំបង្ការ អង្គបដិបក្ខ ក៏កកើតឡើង ការពារប្រឆាំងនឹងការឆ្លងនៃមេរោគគ្រុនផ្តាសាយ។ សូមកត់សំគាល់ថា ថ្នាំបង្ការគ្រុនផ្តាសាយមិនអាចការពារទប់ទល់នឹងជម្ងឺ ដែលមានលក្ខណៈដូចជាគ្រុនផ្តាសាយដែលបង្កឡើងដោយ មេរោគផ្សេងៗទៀតបានឡើយ។

## ការព្យាបាលជម្ងឺគ្រុនផ្តាសាយ

ជាទូទៅ សំរាប់មនុស្សពេញវ័យដែលមានសុខភាពល្អ ពុំចាំបាច់មានការព្យាបាល បែបវេជ្ជសាស្ត្រណាពិតប្រាកដទេ។ ជាធម្មតា ការសំរាកផឹកទឹកអោយបានច្រើន និងការព្យាបាលរោគសញ្ញា និងផលវិបាកនៃជំងឺ គឺជារបៀបទូទៅនៃការព្យាបាល។

ក្រៅពីនេះ បច្ចុប្បន្ននេះ មានឱសថប្រឆាំងនឹងមេរោគបួនប្រភេទផ្សេងៗគ្នា ត្រូវបានបង្កើតឡើង។ ទោះបីមានថ្នាំ Amantadine និង Rimantadine ដែលមានតម្លៃថោក និងងាយរកបានក៏ដោយក៏មានប្រភេទមេរោគគ្រុនផ្តាសាយមួយចំនួន បានស៊ាំនឹងថ្នាំប្រភេទ នេះទៅហើយ។ ចំណែកថ្នាំ Oseltamavir (Tamiflu®) និង Zanamavir (Relenza®) មេរោគពុំសូវធន់បានមែន ប៉ុន្តែវាមានតម្លៃខ្ពស់ ហើយពិបាករកជាងថ្នាំចាស់ៗ។

# ពត៌មានលំអិតអំពីមេរោគគ្រុនផ្តាសាយ

## ប្រភេទមេរោគគ្រុនផ្តាសាយ "ABC"

មេរោគគ្រុនផ្តាសាយ គឺជាមេរោគដែលមានច្រវាក់ ARN ទោលដែលស្ថិតក្នុងអំបូរមេរោគ Orthomyxoviridae។ មេរោគគ្រុនផ្តាសាយទាំងអស់ត្រូវបានបែងចែកជាបីប្រភេទ គឺ A B និង C អាស្រ័យទៅតាមរចនាសម្ព័ន្ធនៃមេរោគ។ មេរោគប្រភេទ A ជាអ្នកទទួលខុសត្រូវ ចំពោះការឆ្លង រាតត្បាតជាសកលដែលនាំអោយគ្រោះថ្នាក់បាត់បង់ជីវិតបាន ចំណែកប្រភេទ B បណ្តាលអោយមានការឆ្លងរាលដាលជម្ងឺតាមតំបន់ដែលមានទ្រង់ទ្រាយតូចជាង។ មេរោគប្រភេទ C មានរោគសញ្ញាមិនសូវធ្ងន់ធ្ងរទេ ហើយពុំសូវកើតមាន ហើយមានភាពហ្នឹងជាងប្រភេទផ្សេងទៀត ។ គ្រុនផ្តាសាយប្រភេទ B និង C ធម្មតាតែងឃើញកើតមាន ចំពោះតែមនុស្សប៉ុណ្ណោះ ។ ប៉ុន្តែចំណែកប្រភេទ A វិញ អាចកើតមានលើទាំងមនុស្ស ទាំងសត្វ រួមទាំងសត្វស្លាប (បក្សាបក្សី) ជ្រូក សេះ ត្រីបាឡែន និងឆ្មាទឹកជាដើម។ គ្រុនផ្តាសាយប្រភេទ A បែងចែកជាអនុប្រភេទផ្សេងៗទៀត ផ្អែកទៅតាមលក្ខណៈអង់ទីហ្សែននៃ glycoproteins ផ្ទៃខាងក្រៅរបស់វា:

- Hemagglutinin (HA)- គឺជាប្រូតេអ៊ីនធំៗ ដែលគ្រប់គ្រងសមត្ថភាព របស់មេរោគដើម្បីចងភ្ជាប់ទៅនឹងចុងសរសៃប្រសាទអាស៊ីដស្យាលីក ដែលទទួលអារម្មណ៍ (sialic acid receptors) នៅលើភ្នាសកោសិកា។

- ប្រសាទរោគ (Neuraminidase-NA)- គឺជាប្រូតេអ៊ីនតូចៗ ដែលគ្រប់គ្រងការបញ្ចេញមេរោគដែល បង្កើតបានថ្មីពីកោសិកា ដោយផ្តាច់ចុងសរសៃប្រសាទអាស៊ីដស្យាលីក ដែលទទួលអារម្មណ៍ (sialic acid receptors)។

មានអនុប្រភេទ HA សំខាន់ៗចំនួនដប់ប្រាំ (ពី H1 ដល់ H15) និង NA ចំនួនប្រាំបួនអនុប្រភេទទៀត (ពី N1 ដល់ N9) ប៉ុន្តែវា អាចចងភ្ជាប់គ្នាបង្កើតបានជាអនុប្រភេទមេរោគមួយចំនួនទៀត ដែលជាធម្មតា អនុប្រភេទខ្លះស្ថិតក្នុងអំបូរតែមួយ។ ឧទាហរណ៍: មេរោគអនុប្រភេទ H1N1 H1N2 និង H1N3 ជាធម្មតា បង្កជម្ងឺគ្រុនផ្តាសាយតែចំពោះមនុស្សប៉ុណ្ណោះ ចំណែកមេរោគប្រភេទ H7N7 និង H3N8 បង្កជម្ងឺចំពោះ សត្វសេះ។ យ៉ាងហោចមានជម្ងឺគ្រុនផ្តាសាយចំនួន15អនុប្រភេទដែលបង្កជម្ងឺចំពោះបក្សាបក្សី ហើយ ប្រភេទដែលរាលដាលលឿនបំផុតនោះ គឺ H5N1។ រហូតមកដល់ពេលថ្មីៗនេះ អនុប្រភេទមេរោគដែល កើតចំពោះបក្សីពុំសូវឃើញមានចំពោះមនុស្ស ឬសត្វ ក្រៅពីជ្រូកឡើយ។

## កាយវិភាគសាស្ត្រនៃមេរោគគ្រុនផ្តាសាយ




| អនុប្រភេទ | H1 | H2 | H3 | H4 | H5 | H6 | H7 | H8 | H9 | H10-15 |
|---|---|---|---|---|---|---|---|---|---|---|
| មនុស្ស | • | • | • | | • | | • | | • | |
| បក្សី | • | • | • | • | • | • | • | • | • | • |
| ជ្រូក | • | | • | | | | | | | |
| សេះ | | | • | | | | • | | | |

មេរោគគ្រុនផ្តាសាយប្រភេទ A អាចបែងចែកជាប្រភេទតូចៗជាច្រើនទៀត ដែល តែងតែវិវឌ្ឍប្រែប្រួលជានិច្ច។ ហើយដោយសារវាមានសមត្ថភាពផ្លាស់ប្តូរលក្ខណៈពន្ធុកម្ម ព្រមទាំងអាចប្តូរហ្សែនជាមួយមេរោគផ្សេងដោយឥតរើសមុខ ដូច្នេះហើយបានជាធ្វើ អោយមេរោគប្រភេទនេះមានលក្ខណៈមិនអាចទស្សន៍ទាយទុកជាមុន ព្រមទាំងអាចបង្ក គ្រោះថ្នាក់ដល់អាយុជីវិតទៀតផង។

| អនុប្រភេទ | ប្រភេទ/សណ្ឋាន | ប្រភេទសត្វ/មនុស្ស ដែលឆ្លងរោគ |
|---|---|---|
| H1N1 | PR/8/34 | មនុស្ស |
| | SW1a/15/30 | ជ្រូក |

## ការវិវឌ្ឍនៅក្នុងមេរោគគ្រុនផ្តាសាយ: ការប្រែប្រួលយឺតៗ និងការប្រែប្រួលលឿននៃអង់ទីហ្សែន

គ្រប់ភាវៈមានជីវិតទាំងអស់សុទ្ធតែមានការផ្លាស់ប្តូរ ប៉ុន្តែមេរោគគ្រុនផ្តាសាយប្រភេទ A ផ្លាស់ប្តូរឆាប់រហ័សជាប់ជានិច្ច ហើយជួនកាលបង្កមហាវិនាសកម្មទៀតផង។ ការផ្លាស់ប្តូរនេះមានពីររបៀប:

- **ការប្រែប្រួលយឺតៗនៃអង់ទីហ្សែន** (Antigenic drift)- នេះជាការក្លែងខ្លួនតូចៗ ជាប់ជាប្រចាំ នៅក្នុងពត៌មានហ្សែននៃមេរោគ។ ដោយសារមេរោគមិនមានលទ្ធភាពអាចជួសជុលការខូចខាតផ្នែកហ្សែន ដែលកើតមានឡើងនៅពេលវាបន្តពូជនោះ មានប្រភេទមេរោគតូចថ្មីៗមកជំនួសមេរោគចាស់ៗជាប្រចាំ។ នៅពេលយើងមានប្រភេទមេរោគតូចៗនៃជម្ងឺគ្រុនផ្តាសាយ យើងក៏បង្កបានជាអង្គបដិបក្ខទប់ទល់នឹង មេរោគនោះប៉ុន្តែអង្គបដិបក្ខទាំងនោះមិនអាចការពារខ្លួនយើងពីមេរោគប្រភេទថ្មីបានឡើយ។ ដូចគ្នានេះដែរ ថ្នាំការពារដែលយើងបានទទួលពីរដូវកន្លងទៅមិនអាចការពារពីមេរោគនៅឆ្នាំនេះបានឡើយ។
- **ការផ្លាស់ប្តូរលឿននៃអង់ទីហ្សែន** (Antigenic shift)- ការណ៍នេះកើតឡើងនៅពេលគ្រុនផ្តាសាយប្រភេទ A បង្កបានជាអនុប្រភេទមកពីប្រភេទផ្សេងៗគ្នា ឧទាហរណ៍ដូចជាមកពីបក្សី និងមនុស្ស ការប្តូរ និងការរួមបញ្ចូលហ្សែនជាដើម ។ ការបង្កាត់ពូជប្រភេទសត្វថ្មីនេះ ត្រូវបានសំរួលដោយ ហ្សេណូម (genome) ដោយចែកជា 08ផ្នែករបស់ជម្ងឺគ្រុនផ្តាសាយ។ លទ្ធផលនៃការបង្កាត់នេះបានជា ប្រភេទមេរោគថ្មីបានមកពីមេរោគជាមេបាណាមួយ។ ដោយសារពុំមានភាពស៊ាំធម្មជាតិណាមួយទប់ទល់នឹងប្រភេទមេរោគទាំងនេះ នោះវាអាចរាលដាលបានយ៉ាងឆាប់រហ័ស បង្កអោយមានជម្ងឺរីករាលដាល និងការស្លាប់។ ប្រសិនបើអនុប្រភេទដើមនៃគ្រុនផ្តាសាយ ជាមេរោគគ្រុនផ្តាសាយនៅក្នុងខ្លួនមនុស្សនោះ មេរោគថ្មីមានលទ្ធភាពអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតយ៉ាងងាយស្រួល ហើយអាចក្លាយជាជំងឺឆ្លងរីករាលដាលពេញពិភពលោកបានទៀតផង។

គេបានគិតថា ការផ្លាស់ប្តូរនៃអង់ទីហ្សែន ជាធម្មតាកើតឡើងពីមនុស្សដែលរស់នៅជិតកន្លែងចិញ្ចឹមបសុបក្សីនិង ជ្រូក ។ ដោយសារជ្រូកងាយនឹងឆ្លងទាំងមេរោគបក្សី និង ទាំងមេរោគថនិកសត្វនោះរួម ទាំងប្រភេទមេរោគនៅក្នុងខ្លួនមនុស្សផងដែរនោះ ជ្រូកអាចជា "កន្លែងបង្កាត់មេរោគ" សំរាប់ ច្របល់សមាសធាតុហ្សែនពីមនុស្ស និង មេរោគបក្សី នាំអោយកើតមានជាមេរោគអនុប្រភេទថ្មីហើយចម្លែក ។ ទោះជាយ៉ាងណាក៏ដោយ តាមព្រឹត្តិការណ៍ថ្មីៗនេះ បានរកឃើញយន្តការទីពីរដែលអាចកើតមានឡើងបាន ។ ភស្តុតាង បង្ហាញថា យ៉ាងហោចណាស់មានអនុប្រភេទមេរោគគ្រុនផ្តាសាយបក្សីចំនួន15 កំពុងតែឆ្លងរាលដាលក្នុងចំណោមបក្សីហើយមនុស្សផ្ទាល់ក៏អាចជា "កន្លែងបង្កាត់មេរោគ" ផងដែរ ។

# ការប្រែប្រួលយឺតៗនៃអង់ទីហ្សែន




*–ធ្វើបច្ចុប្បន្នភាពនៅ ថ្ងៃទី30 ខែធ្នូ ឆ្នាំ2005*